

វេទិកាពលរដ្ឋខ្មែរដើម្បីប្រជាធិបតេយ្យ៖

# ពេលនេះ ទៅមុខ គោលដៅយើង ត្រូវធ្វើអ្វីទៀត?

ថ្ងៃសៅរ៍ ទី១៥ ខែកក្កដា ឆ្នាំ២០២៣

## រៀបបង្កើតការផ្លាស់ប្តូរមួយប្រកប ដោយអត្ថន័យ និងប្រសិទ្ធភាព

# ទទួលស្គាល់ដោយ

វេទិកានេះបានប្រមូលផ្តុំក្រុមចម្រុះជាច្រើន និងប្រជាពលរដ្ឋមកពីគ្រប់ទិសទី ដែលមានចក្ខុវិស័យរួមគ្នា ចំពោះសេរីភាព លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ បទពិសោធន៍រួម និងគោលបំណងរបស់អ្នកចូលរួមទាំងអស់ បានផ្តុំគ្នាជាការជំរុញទឹកចិត្តមួយ ដែលញ៉ាំងឲ្យវេទិកានេះអាចប្រព្រឹត្តទៅបាន។

យើងទាំងអស់គ្នា កំពុងតែត្រៀមចេញដំណើររួមគ្នាមួយ ដែលបុគ្គលម្នាក់ៗសុទ្ធតែមានតួនាទីសំខាន់បំផុតតែរៀងៗខ្លួន ក្នុងការត្រួសត្រាយផ្លូវទៅកាន់អនាគតភ្លឺស្វាងសម្រាប់ប្រទេសកម្ពុជា។ ផ្លូវដើរថ្មីនេះ ត្រូវបានគូសវាសដោយការតាំងចិត្ត ពីសំណាក់បងប្អូនទាំងអស់ ដែលបានមករួមគ្នា ក្នុងការបង្កើតឲ្យមានវេទិកានេះឡើង។

# គោលការណ៍ណែនាំនេះ បង្ហាញអំពីជំហានចាំបាច់ និងសកម្មភាពតស៊ូមតិ ដែលយើងជាសហគមន៍ខ្មែរ ត្រូវប្រកាន់យក ដើម្បីបង្កើតប្រទេសកម្ពុជាមួយ ដែលយើងចង់បាន គឺសង្គមមួយដែលមានភាពសេរី និងយុត្តិធម៌។

“ការហ៊ាននិយាយការពិតអំពីការដឹកនាំមិនត្រឹមត្រូវ” គឺជាជំហានដំបូង និងជាការចាំបាច់ខ្លាំងមួយ ដែលយើងត្រូវប្រកាន់យក។ ទោះជាយ៉ាងនេះក្តី យើងត្រូវចងចាំថា ដំណើរការបង្កើតឲ្យមានការផ្លាស់ប្តូរមួយប្រកបដោយអត្ថន័យ និងប្រសិទ្ធភាព ទោះជានៅប្រទេសណាក៏ដោយ រួមទាំងប្រទេសកម្ពុជាផង គឺត្រូវការពេលយូរ។

ពុំមានគំនិតផ្តួចផ្តើម សកម្មភាព ទីភ្នាក់ងារ ឬបុគ្គលណាម្នាក់ នឹងអាចដោះស្រាយបញ្ហាទាំងនេះបាន ដោយម្នាក់ឯងនោះឡើយ។ វាតម្រូវឲ្យខ្មែរយើងរាល់គ្នា នៅក្នុងសហគមន៍ទាំងក្នុងនាមជាបុគ្គលម្នាក់ៗ និងទាំងក្នុងនាមជាសមូហភាព ធ្វើការជាមួយគ្នា។ សេរីភាព ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ពុំមែនជារបស់បានដោយងាយៗនោះទេ។

យើងត្រូវរៀបចំ ការខំតស៊ូមតិរបស់យើង ឲ្យមានជាលំដាប់លំដោយ មានជាប់ជាប្រចាំ យូរអង្វែង និងគ្រប់ជ្រុងជ្រោយ ដើម្បីបង្កើតឲ្យមានការផ្លាស់ប្តូរប្រកបដោយអត្ថន័យ និងចីរភាព។



# អ្វីខ្លះដែលបានកើតឡើងមកដល់ពេលនេះ

## ពិនិត្យមើលកិច្ចការរបស់អង្គការសហប្រជាជាតិ ស្តីពីកម្ពុជា

ក្នុងរយៈពេលមួយឆ្នាំមកនេះ អង្គការសហប្រជាជាតិបានបំពេញតួនាទីនាំមុខ ដែលមិនធ្លាប់មាន និងដោយពេញទំហឹង ក្នុងការថ្កោលទោសសកម្មភាពរំលោភបំពាន និងផ្តាច់ការរបស់របបលោក ហ៊ុន សែន។

នៅក្នុងរបាយការណ៍ជាដំណាក់កាល និងសេចក្តីថ្លែងការណ៍ ដែលបានធ្វើនៅកំម្រិតខ្ពស់បំផុត អង្គការសហប្រជាជាតិបានបញ្ជាក់ជំហរយ៉ាងច្បាស់លាស់ថា លោក ហ៊ុន សែន បានរំលោភបំពានសិទ្ធិមនុស្ស នីតិរដ្ឋ និងបទដ្ឋានប្រជាធិបតេយ្យ ដោយធ្វើសកម្មភាពរំលោភបំពានមូលដ្ឋានគ្រឹះជាប្រព័ន្ធមួយ។ គាត់បានលុបបំបាត់ចោលគណបក្សប្រឆាំងដែលធំជាងគេ ចាប់មេដឹកនាំរបស់គណបក្សនេះដាក់ពន្ធនាគារ ដោយកាត់ក្តីរឿងព្រហ្មទណ្ឌម្តងមានមនុស្សច្រើនគ្នាជាទ្រង់ទ្រាយធំ បិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងបំផ្លាញអង្គការសង្គមស៊ីវិល។ ប្រការទាំងនេះ ធ្វើឲ្យការបោះឆ្នោតមួយប្រកបដោយភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌ ពុំអាចកើតមានទៅរួច។

អង្គការសហប្រជាជាតិ បានចេញ“ផែនការសកម្មភាពនៃវិធានការកែទម្រង់”មួយ ដោយទាមទារឲ្យមានការកែទម្រង់ ពីរដ្ឋាភិបាលោក ហ៊ុន សែន ដែលត្រូវការជាចាំបាច់ ដើម្បីធ្វើឲ្យការបោះឆ្នោតនៅកម្ពុជា ប្រព្រឹត្តទៅដោយមានភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌។

ក្នុងចំណោមការទាមទារឲ្យមានការកែទម្រង់ទាំងនោះ មានដូចខាងក្រោម៖

១) លុបចោលសេចក្តីសម្រេច ដែលប្រកាសចាត់ទុកគណបក្សប្រឆាំងថាជាគណបក្សខុសច្បាប់ និងត្រូវអនុញ្ញាតឲ្យមានសកម្មភាពគណបក្សប្រឆាំង ប្រកបដោយអត្ថន័យ។

២) បញ្ចប់ការជំនុំជម្រះក្តីទ្រង់ទ្រាយធំ ពាក់ព័ន្ធនឹងមេដឹកនាំគណបក្សប្រឆាំង និងអ្នកដទៃទៀតដែលហ៊ាននិយាយរិះគន់រដ្ឋាភិបាល និង

៣) អនុញ្ញាតឲ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បើកដំណើរការឡើងវិញនិងបំពេញមុខងាររបស់ខ្លួន ដោយពុំមានការជ្រៀតជ្រែក។

# អ្វីដែលបានកើតឡើងមកដល់ពេលនេះ

## ពិនិត្យមើលកិច្ចការតស៊ូមតិរបស់សហគមន៍ខ្មែរកាលពីមុន

### ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០

ដាក់"បញ្ជីរាយនាមបញ្ហា" ទៅកាន់គណៈកម្មាធិការអង្គការសហប្រជាជាតិ ដោយអនុលោមតាមអនុញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សម្រាប់ខែមីនា ឆ្នាំ២០២២

### ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១

កិច្ចប្រជុំតាមប្រព័ន្ធអ៊ិនធើណិត ដើម្បីចែករំលែកព័ត៌មាន និងផែនការយុទ្ធសាស្ត្រ តាមប្រព័ន្ធវីដេអូ **ZOOM** ជាមួយលោក ប្រ៊ែដ អាដាមស៍ **(BRAD ADAMS)**

### ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១

វគ្គទីមួយរបស់គណៈកម្មការស៊ើបអង្កេតកម្ពុជា៖ ការរម្លឹកខួប ៣០ឆ្នាំ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១

### ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២

អន្តរាគមន៍ផ្ទាល់មាត់អំពី "ចំណាត់ការបន្ទាន់ត្រូវការជាចាំបាច់ ស្តីពីការរំលោភបំពានប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា" ទៅកាន់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដោយអនុលោមតាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

### ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២

វគ្គទីពីរបស់គណៈកម្មការស៊ើបអង្កេតកម្ពុជា៖ វគ្គពិសេស

### ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២

យុទ្ធនាការនៃសញ្ញាណព្រមានអំពីករណីចំណាត់ការបន្ទាន់របស់ខ្មែរ និងយុទ្ធនាការសហគមន៍ខ្មែរ

### ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២

វគ្គផ្តល់ព័ត៌មានក្រៅផ្លូវការ ជាមួយគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

### * ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានចេញរបាយការណ៍ "ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា"

### ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២

វគ្គទីបីរបស់គណៈកម្មការស៊ើបអង្កេតកម្ពុជា៖ នីតិរដ្ឋ

### *តុលា ៥, ២០២២

* អង្គការសហប្រជាជាតិ ដាក់បង្ហាញ "ផែនការសកម្មភាពនៃវិធានការកែទម្រង់" សម្រាប់រដ្ឋាភិបាលកម្ពុជា យកទៅអនុវត្តនៅមុនការបោះឆ្នោតជាតិនាខែ កក្កដា ឆ្នាំ ២០២៣ (A/HRC/51/66)

### ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣

ដាក់"សំណើឲ្យដាក់ឯកសារ" ស្តីអំពី "ផែនការសកម្មភាពនៃវិធានការកែទម្រង់" សម្រាប់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ វគ្គត្រួតពិនិត្យលើកទី៥៤ សម្រាប់ខែកញ្ញា/តុលា ឆ្នាំ ២០២៣

*អក្សរពណ៌ទឹកក្រូចគឺជា របាយការណ៍របស់អង្គការសហប្រជាជាតិ



# ពីនេះទៅមុខ គោលដៅយើងត្រូវធ្វើអ្វីទៀត?

## កិច្ចខិតខំតស៊ូមតិរបស់ខ្មែរនៅពេលឆាប់ៗខាងមុខ

ព្រឹត្តិការណ៍អាក្រក់ជាបន្តបន្ទាប់ បានញាំងឲ្យមានចម្ងល់ក្នុងចិត្តឥតស្បើយរបស់ពលរដ្ឋខ្មែរនៅទូទាំងពិភពលោក អំពីថាតើ“ពីពេលនេះទៅមុខ គោលដៅយើងត្រូវធ្វើអ្វីទៀត**?**”។ តើជំហានតស៊ូមតិអ្វីខ្លះ ដែលចាំបាច់ត្រូវប្រកាន់យក នៅពេលឆាប់ៗខាងមុខ ដើម្បីទប់ទល់នឹងលទ្ធផលនៃការបោះឆ្នោតមិនត្រឹមត្រូវ និងដើម្បីបង្កើតឲ្យមានការផ្លាស់ប្តូរប្រកបដោយអត្ថន័យ និងប្រសិទ្ធភាព សម្រាប់កម្ពុជា**?** ក្នុងចំណោមការខំប្រឹងប្រែងតស៊ូមតិនាពេលឆាប់ៗខាងមុខ ដែលយើងស្នើឲ្យធ្វើ និងចាត់ទុកជា“ជំហានបន្ទាប់” គឺមានដូចតទៅនេះ៖

១) ការចូលរួមសកម្មជាមួយការត្រួតពិនិត្យកម្ពុជារបស់អង្គការសហប្រជាជាតិ (ឧទាហរណ៍ ការត្រួតពិនិត្យជាសកលតាមកាលកំណត់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ)

២) នៅថ្ងៃទី០១ ខែវិច្ឆិកា នឹងមានកិច្ចប្រជុំរៀបចំផែនការយុទ្ធសាស្ត្រជាមួយអ្នកជំនាញអន្តរជាតិ

៣) នៅថ្ងៃទី២៣ ខែកញ្ញា អង្គការសហប្រជាជាតិ នឹងទទួលបណ្តឹងស្តីពីកម្ពុជា ពីអង្គការក្រៅរដ្ឋាភិបាល ដែលជាផ្នែកនៃដំណើរការត្រួតពិនិត្យជាសកលតាមកាលកំណត់ (សូមមើលថ្ងៃទី០១ ខែកញ្ញា)

៤) ដាក់ទណ្ឌកម្មទៅលើ ពាណិជ្ជកម្មនៅកម្ពុជា

៥) រៀបចំអោយអ្នកប្រើប្រាស់ធ្វើពហិកា និង

៦) រៀបចំពហិការផ្នែកទេសចរណ៍

# សូមរក្សាកាលបរិច្ឆេទទុក

## កិច្ចខិតខំតស៊ូមតិរបស់សហគមន៍ខ្មែរ ដែលចូលមកដល់ក្នុងពេលឆាប់ៗ

### ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣

វេទិកាពលរដ្ឋខ្មែរដើម្បីប្រជាធិបតេយ្យ: "ពីនេះទៅមុខ គោលដៅយើងត្រូវធ្វើអ្វីទៀត?"
**HYBRID FORUM**

### ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៣

វគ្គទីបួនរបស់គណៈកម្មការស៊ើបអង្កេតកម្ពុជា៖ ការបោះឆ្នោតជាតិ

### ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣

ដាក់របាយការណ៍ “ត្រួតពិនិត្យជាសកលតាមកាលកំណត់” ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សម្រាប់ខែមេសា ឆ្នាំ ២០២៤

### ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣

វគ្គទីប្រាំរបស់គណៈកម្មការស៊ើបអង្កេតកម្ពុជា៖ វគ្គបោះឆ្នោតពិសេស “ពេលនេះទៅមុខ គោលដៅយើងត្រូវធ្វើអ្វីទៀត?”

### ខែកញ្ញា/តុលា ឆ្នាំ២០២៣

វគ្គត្រួតពិនិត្យលើកទី៥៤ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

### ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣

“វគ្គរៀបចំផែនការយុទ្ធសាស្ត្រនៃអ្នកជំនាញអន្តរជាតិ នៅក្រោយការបោះឆ្នោតជាតិដែលមិនត្រឹមត្រូវនៅកម្ពុជា”

### ខែមេសា ឆ្នាំ២០២៤

វគ្គទី៥៥ នៃកិច្ចប្រជុំត្រួតពិនិត្យជាសកលតាមកាលកំណត់ស្ដីពីកម្ពុជារបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

### ខែមេសា ឆ្នាំ២០២៤

សហភាពអឺរ៉ុបដែលភាគីពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងកិច្ចប្រជុំស្ថាប័នសិទ្ធិមនុស្សជាតិ



# ការចេញដំណើរលើគន្លងផ្លូវថ្មី

## ចាប់យកឱកាសសម្រាប់ឲ្យមានការផ្លាស់ប្តូរប្រកដដោយអត្ថន័យ នៅកម្ពុជា

ការបោះឆ្នោតជាតិនាខែកក្កដា ឆ្នាំ២០២៣ គូសបញ្ជាក់អំពីពេលវេលាដ៏សំខាន់បំផុតមួយ ក្នុងការបន្តស្វែងរកយុត្តិធម៌ និងប្រជាធិបតេយ្យ។

យើងពុំទទួលយកលទ្ធផលបោះឆ្នោត ដែលត្រូវបានគេរៀបចំទុកមុនរួចជាស្រេច និងដែលត្រូវបានគេសម្រេចទុកមុននេះនោះឡើយ។ ចំណាត់ការរបស់អង្គការសហប្រជាជាតិ បង្ហាញឲ្យឃើញយ៉ាងច្បាស់ក្រឡែត និងដោយពេញទំហឹង ក្នុងការជំទាស់ទៅនឹងរបស់លោក ហ៊ុន សែន។ ជំហរបស់អង្គការសហប្រជាជាតិ ផ្តល់ឲ្យយើងនូវផ្លូវដើរ និងក្តីសង្ឃឹមថ្មីសម្រាប់ឲ្យមានការផ្លាស់ប្តូរមួយ។ អង្គការសហប្រជាជាតិ បានបោះដៃមកគាំទ្រយើង និងផ្តល់ឱកាសឲ្យយើង។ ឥឡូវនេះ វាអាស្រ័យលើការទទួលខុសត្រូវរបស់យើង ក្នុងការចាប់យកឱកាសនេះ និងពង្រឹងសក្តានុពលដើម្បីឲ្យមានការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាពមួយ។

ការបោះឆ្នោតជាតិនៅកម្ពុជា ដែលស្ថិតក្នុងការត្រួតត្រាយ៉ាងតឹងរឹងនោះ គឺកើតឡើងគាប់ជួនគ្នានឹងបញ្ហារំលោភសិទ្ធិមនុស្សជាប្រព័ន្ធ និងការបំពាននីតិរដ្ឋ ដែលរដ្ឋាភិបាលលោក ហ៊ុន សែន បានបង្កើត។ ប្រការនេះ បង្ករឲ្យមានបញ្ហាប្រឈមយ៉ាងខ្លាំង សម្រាប់សហគមន៍ខ្មែរ។ ប៉ុន្តែបញ្ហានេះ វាផ្តល់ជាឱកាសពិសេសទៅវិញ សម្រាប់ស្វែងរកច្រកចេញដែលមានប្រសិទ្ធភាព ក្នុងការលើកស្ទួយឲ្យមានការផ្លាស់ប្តូរប្រកបដោយអត្ថន័យ និងដើម្បីរៀបចំឲ្យសហគមន៍ខ្មែរ និងប្រទេសកម្ពុជានាពេលអនាគត ដើរត្រូវតាមគន្លងសិទ្ធិមនុស្ស នីតិរដ្ឋ និងប្រជាធិបតេយ្យ។ សូមអញ្ជើញចូលរួមទាំងអស់គ្នា ដើម្បីយើងធ្វើដំណើរលើគន្លងផ្លូវនេះ!

# គណៈកម្មការស៊ើបអង្កេតកម្ពុជា

## សវនាការស្វែងរកការពិតកម្ពុជា

### ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ វគ្គបើចំហជាសាធារណៈ

វគ្គនេះធ្វើឡើងគាប់ជួនគ្នាជាមួយការរម្លឹកខួបទី ៣០ឆ្នាំ នៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ដែលមានបញ្ចូលបទដ្ឋានជាស្នូលនៃប្រជាធិបតេយ្យ និងសិទ្ធិសមនុស្ស សម្រាប់រដ្ឋាភិបាលកម្ពុជា។ លោក ហ៊ុន សែន ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនោះ បានយល់ព្រមទៅនឹងបទដ្ឋានដែលបានបង្កើតឡើងជាអន្តរជាតិទាំងនោះ។ ចំណុចពិសេសដែលត្រូវបញ្ជាក់បន្ថែម គឺផ្តោតលើសារសំខាន់នៃការមានសក្ខីកម្មរបស់ជនរងគ្រោះ។

### ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២ វគ្គពិសេស

សវនាការលើកទីពីរ ធ្វើឡើងគាប់ជួនគ្នានឹងវគ្គត្រួតពិនិត្យអំពីការអនុវត្តតាមជាពិសេស ស្តីពីកម្ពុជា ដោយគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ វគ្គនេះផ្តោតលើសារសំខាន់ នៃកិច្ចខិតខំប្រឹងប្រែងរួមគ្នា កិច្ចសហប្រតិបត្តិការ និងផែនការសកម្មភាព ក្នុងចំណោមទីភ្នាក់ងារអន្តរជាតិ និងការដាក់ឲ្យដំណើរការបណ្តាញសកម្មភាពបន្ទាន់របស់ខ្មែរ ដើម្បីទាញចំណាប់អារម្មណ៍អន្តរជាតិ សម្របសម្រួលសកម្មភាពកែតម្រូវប្រកបដោយប្រសិទ្ធភាព និងដោះស្រាយដោយសកម្មលើករណីជាក់លាក់ និងបញ្ហាបន្ទាន់។

### ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២ វគ្គនីតិរដ្ឋ

វគ្គនេះគូសបញ្ជាក់អំពីការណ៍ដែលរដ្ឋាភិបាលលោក ហ៊ុន សែន បំផ្លាញនីតិរដ្ឋ និងគ្រប់គ្រងប្រព័ន្ធតុលាការ ដើម្បីបន្តរក្សាអំណាច ដែលមិនអាចឲ្យនរណាតវ៉ាបាន។ វគ្គនេះក៏សង្កត់ធ្ងន់លើមូលហេតុដែលរដ្ឋាភិបាលកម្ពុជា មិនសមទទួលបានបានការគាំទ្រពីអន្តរជាតិ និងបញ្ជាក់អំពីសារសំខាន់បំផុត ក្នុងការដាក់ឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះអំពើរំលោភបំពានរបស់ខ្លួន។

### ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៣ វគ្គបោះឆ្នោតជាតិ

ផ្អែកលើការរកឃើញរបស់អង្គការសហប្រជាជាតិ និងគណៈកម្មការស៊ើបអង្កេត យើងកំពុងប្រឈមមុខនឹងការពិតដ៏ស្រឡះដែលថា ការបោះឆ្នោតនាពេលខាងមុខនឹងមិនត្រូវបានគេចាត់ទុកថាសេរី យុត្តិធម៌ ឬស្របច្បាប់នោះទេ ដោយសារការរំលោភសិទ្ធិមនុស្ស និងនីតិរដ្ឋជាប្រព័ន្ធដោយ ហ៊ុន សែន។

### ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣ វគ្គពិសេសអំពីការបោះឆ្នោត៖ ពេលនេះទៅមុខ គោលដៅយើងត្រូវធ្វើអ្វីទៀត?

សវនាការឆ្លើយតបទៅនឹងរាល់សំណួរសំខាន់ៗ អំពីអ្វីខ្លះជាជំហានដែលត្រូវប្រកាន់យក ដើម្បីដោះស្រាយជាមួយនឹងការបោះឆ្នោតបែបក្លែងក្លាយ និងមិនស្របច្បាប់ ដូចអ្វីដែលអង្គការសហប្រជាជាតិបានគូសបញ្ជាក់។



# សហគមន៍ខ្មែរ
# អំពាវនាវឱ្យធ្វើសកម្មភាព

### ការប្តេជ្ញាតស៊ូមតិរបស់សហគមន៍ខ្មែរ

ការប្តេជ្ញាតស៊ូមតិរបស់សហគមន៍ខ្មែរ គឺជាការប្តេជ្ញាចិត្តមួយ ដើម្បីប្រើប្រាស់គ្រប់ទម្រង់ និងវេទិកាដែលមាន នៅកម្រិតអន្តរជាតិ ដើម្បីធ្វើយ៉ាងណាឲ្យប្រទេសកម្ពុជា បំពេញត្រូវតាមបទដ្ឋានអន្តរជាតិ ផ្នែកលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ។

"ខ្ញុំ ______________________ សូមទទួចឲ្យសហគមន៍ខ្មែរនៅទូទាំងពិភពលោក ចាត់វិធានការចាំបាច់នានា និងសកម្មភាពតស៊ូមតិ ដែលត្រូវធ្វើដើម្បីបង្កើតឲ្យមានការផ្លាស់ប្តូរមួយប្រកបដោយអត្ថន័យ និងប្រសិទ្ធភាព សម្រាប់ប្រទេសកម្ពុជា ដែលយើងឃើញឲ្យមាន នោះគឺសង្គមមួយដែលមានសេរីភាព និងយុត្តិធម៌"។

បងប្អូនដែលមកចូលរួមដោយផ្ទាល់ អាចចុះហត្ថលេខាលើការប្តេជ្ញារបស់សហគមន៍ខ្មែរនេះ នៅតុសម្រាប់ការតស៊ូមតិ នៅកន្លែងទទួលភ្ញៀវ។

ចំពោះបងប្អូនដែលចូលរួមតាមប្រព័ន្ធ **Zoom** បងប្អូនអាចចុះហត្ថលេខាលើការប្តេជ្ញានេះបាន នៅតាមរយៈគេហទំព័រ**savecambodia.org**។ បងប្អូនអាចទទួលបានលិខិតបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់សហគមន៍ខ្មែរនេះ តាមអ៊ីម៉េល តាមប្រៃសនីយ៍ ឬតាមមធ្យោបាយទាំងពីរនេះ។ បងប្អូនដែលរស់នៅប្រទេសកម្ពុជា នឹងមិនអាចទទួលបានលិខិតបញ្ជាក់នេះ តាមប្រៃសនីយ៍នោះឡើយ។ ប៉ុន្តែបងប្អូនអាចជ្រើសវិធីទទួលវា តាមអ៊ីម៉េល ឬប្រព័ន្ធទំនាក់ទំនងសង្គម **Signal, WhatsApp** ឬ **Facebook Messenger**។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកស្រី
**Nalen.Smith@savecambodia.org**

# អនាគតប្រទេសកម្ពុជាឋិតក្នុង
# កណ្ដាប់ដៃរបស់បងប្អូន

ជម្រើសមានតែមួយគត់គឺ
ត្រូវធ្វើសកម្មភាព




## ទំនាក់ទំនងទូរទៅ

សម្បត្តិ វ៉េត | SONSANDDAUGHTERSKH@GMAIL.COM
នីកូល អ៊ឹង | BORASMYUNG1@GMAIL.COM
ទឹង យ៉ាប់ |TUNG@CAHRAD.ORG

## ទំនាក់ទំនងជាបន្ទាន់តាមបណ្ដាញសកម្មភាពខ្មែរ

សីលា ញាន | SEYLA.NHEAN@SAVECAMBODIA.ORG

## ទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយ

កុលវ័ឌ្ឍក៍ សោម | KOLVATH.SOM@SAVECAMBODIA.ORG